01000141

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 21 / 07 / 2014
ម៉ោង (Time/Heure) : 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E307/3/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**សាធារណៈ / Public**

## អង្គជំនុំជម្រះសាលាដំបូង

**ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១៤**

**ជូនចំពោះ:** **ភាគីទាំងអស់ក្នុងសំណុំរឿង ០០២**

**ពី:** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ:** **សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមចំនួនទំព័រដើម្បីធ្វើយុត្តិកម្មអំពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន៨៧ (៤) នៃវិធានផ្ទៃក្នុង**

1. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើរបស់ការិយាល័យសហព្រះរាជអាជ្ញាសុំបន្ថែមចំនួនទំព័រលើសចំនួនទំព័រដែលបានកំណត់សម្រាប់ការដាក់សារណារបស់ខ្លួនអនុលោមតាមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង (ឯកសារ E307/3)។ សហព្រះរាជអាជ្ញាបានលើកឡើងករណីថា ដោយសារតែសហ-ព្រះរាជអាជ្ញាត្រូវបានតម្រូវឱ្យដាក់សារណាដែលមានសំអាងហេតុសម្រាប់ការទទួលយកបុគ្គលថ្មីៗទាំងអស់ដែលត្រូវបានស្នើសុំក្រោយសវនាការបឋមកាលពីខែ មិថុនា ឆ្នាំ ២០១១ (ឯកសារ E307/1) និងដោយសារ តែពេលថ្មីៗនេះ សហព្រះរាជអាជ្ញាបានស្នើសុំបុគ្គល ៣៥ នាក់ ដែលមិនត្រូវបានស្នើសុំនៅមុនពេលចាប់ផ្តើមសំណុំរឿង ០០២ (E307) នោះ ហេតុដូចនេះ សហព្រះរាជអាជ្ញាត្រូវការបន្ថែមចំនួនទំព័រលើសពីចំនួនកំណត់ដែលអនុញ្ញាតដោយ *សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ*

*អ.វ.ត.ក* ដើម្បីអាចធ្វើយុត្តិកម្មអំពីការដាក់បញ្ចូលបុគ្គលទាំងនេះ។ អាស្រ័យហេតុនេះ សហព្រះរាជ-អាជ្ញាស្នើសុំការអនុញ្ញាតដាក់សារណាសរុបចំនួន ៤៥ ទំព័រ ជាភាសាអង់គ្លេស ដោយរួមបញ្ចូលបុគ្គលទាំង ៣៥ រូបនេះ។

2. អង្គជំនុំជម្រះសាលាដំបូងឯកភាពតាមសំណើសុំរបស់សហព្រះរាជអាជ្ញា ដោយអង្គជំនុំជម្រះយល់ឃើញថា មូលហេតុដែលសហព្រះរាជអាជ្ញាលើកឡើងសម្រាប់ការបន្ថែមចំនួនទំព័រទៅលើចំនួនកំណត់ គឺជាកាលៈទេសៈពិសេស។ អង្គជំនុំជម្រះយល់ឃើញថា ដើម្បីជាផលប្រយោជន៍យុត្តិធម៌ព្រមទាំងដើម្បីប្រសិទ្ធភាពផ្នែកនីតិវិធី និងការរៀបចំ ភាគីនីមួយៗអាចដាក់សារណារួមតែមួយអនុ-លោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដែលរួមបញ្ចូលបុគ្គលទាំងអស់ដែលមិនត្រូវបានស្នើសុំនៅមុនពេលចាប់ផ្តើមសំណុំរឿង ០០២។ ដោយពិចារណាទៅលើសំណើបច្ចុប្បន្នរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យបញ្ចូលបុគ្គលថ្មីចំនួន ១៨ រូប(ឯកសារ E307/1.1) អង្គជំនុំ-ជម្រះស្នើឱ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដាក់សារណាមិនឱ្យលើសពី ៣០ ទំព័រជាភាសាអង់គ្លេស ឬភាសាបារាំង ឡើយ។

3. ការបន្ថែមចំនួនទំព័រលើសពីចំនួនកំណត់នេះ អនុវត្តតែលើសំណើអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងដែលភាគីស្នើសុំស្តាប់សក្ខីកម្មបុគ្គលដែលមិនត្រូវបានស្នើឡើងនៅពេលចាប់ផ្តើមសំណុំ-រឿង ០០២ តែប៉ុណ្ណោះ។ អង្គជំនុំជម្រះស្នើឱ្យភាគីនានាដាក់សំណើសុំ អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង ឱ្យបានឆាប់រហ័ស ដើម្បីជួយសម្រួលដល់ការចាប់ផ្តើមសវនាការពិនិត្យភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០២។